ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លេខ ៖ ......១៥៤២.......អ.ជ.ប.ជ.អ

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦

## សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

* * * * * * * * * * *

## ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខសន.រតក ០១០០-០០៧ ចុះថ្ងៃទី១៣ ខែមករាឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្របក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- យោងគំរោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយពហុវិស័យ ដើម្បីឆ្លើយតបទៅនឹងការការរីករាលដាលនៃមេរោគអេដស៍ ជំងឺអេដស៍ ២០១៥ - ២០២០
- យោងសេចក្តីសម្រេចរបស់អង្គប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦

## សម្រេច

**ប្រការ១**: បង្កើតក្រុមប្រឹក្សាភិបាលសំរាប់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១. ឯកឧត្តមវេជ្ជ.តែង គន្ធី | អគ្គលេខាធិការអ.ជ.ប.ជ.អ | ប្រធាន |
| ២. លោកវេជ្ជ. វ៉ុង យ៉ាណាត | ប្រធាននាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ | ជំនួយការ |
| ៣.លោកវេជ្ជ. អ៊ឹង សុវណ្ណៈ | អនុប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ | សមាជិក |
| ៤. តំណាង | អង្គការUNAIDS | សមាជិក |
| ៥. តំណាង | អង្គការFHI360 | សមាជិក |

៦. តំណាង អង្គការKHANA សមាជិក

**ប្រការ២**: ក្រុមប្រឹក្សាភិបាលសំរាប់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានតួនាទី និងភារៈកិច្ចដូចខាងក្រោម:

- ស្វែងរកការគាំទ្រ និងចលនាប្រភពធនធានសំរាប់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍
- តាមដានការអនុវត្តន៍នូវគោលនយោបាយ ផែនការយុទ្ធសាស្រ្ត និងផែនការប្រតិបត្តិ ដែលទាក់ទងនឹងក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។
- ការផ្តល់អនុសាសន៍សំរាប់បទអន្តរាគមន៍បង្ការ និងគាំទ្រដល់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។
- ធ្វើការពិនិត្យ និងផ្តល់ជាអនុសាសន៍ក្នុងការរៀបចំផែនការយុទ្ធសាស្រ្ត និងផែនការប្រតិបត្តិទាក់ទងក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

**ប្រការ៣**: កែសម្រួលក្រុមការងារបច្ចេកទេសថ្នាក់ជាតិ សំរាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានសមាសភាពដូចខាងក្រោម:

១.លោកវេជ្ជ. វ៉ឹង យ៉ាណាត អ.ជ.ប.ជ.អ ប្រធាន

២.តំណាងមជ្ឈលមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើរស្បែក និងកាមរោគ អនុប្រធាន

៣.លោកវេជ្ជ. អ៊ឹង សុវណ្ណៈ ទទូលបន្ទុក ការងារMSM&TG(អ.ជ.ប.ជ.អ) អនុប្រធាន

៤.តំណាង ក្រសួងការពារជាតិ សមាជិក

៥.តំណាង ក្រសួងមហាផ្ទៃ សមាជិក

៦.តំណាង ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៧.តំណាង ក្រសួងធម្មការ និងសាសនា សមាជិក

៨.តំណាង ក្រសួងអប់រំ យុវជន និងកីឡា

៩.តំណាង ក្រសួងការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈ សមាជិក

១០.តំណាង ក្រសួងវប្បធម៌ និងវិចិត្រសីល្បៈ សមាជិក

១១.តំណាង ក្រសួងព័ត៌មាន សមាជិក

១២.តំណាង ក្រសួងទេសចរណ៍ សមាជិក

១៣.តំណាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៤.តំណាង លេខាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ សមាជិក

| | | |
|---|---|---|
| ១៥.តំណាង | អង្គការUNAIDS | សមាជិក |
| ១៦.តំណាង | អង្គការFHI360 | សមាជិក |
| ១៧.តំណាង | អង្គការKHANA | សមាជិក |
| ១៨.តំណាង | អង្គការPSK | សមាជិក |
| ១៩.តំណាង | អង្គការRHAC | សមាជិក |
| ២០.តំណាង | អង្គការMHSS | សមាជិក |
| ២១.តំណាង | អង្គការMHC | សមាជិក |
| ២២.តំណាង | អង្គការKHEMERA | សមាជិក |
| ២៣.តំណាង | អង្គការAHF | សមាជិក |
| ២៤.តំណាង | អង្គការSIT | សមាជិក |
| ២៥.តំណាង | អង្គការPSC(អង្គការកម្ពុជាបំបាត់ឈឺចាប់) | សមាជិក |
| ២៦.តំណាង | បណ្តាញអ្នកផ្ទុកមេរោគអេដស៍(CPN+) | សមាជិក |
| ២៧.តំណាង | បណ្តាញចតុមុខ(BC network) | សមាជិក |
| ២៨.តំណាង | ROCK | សមាជិក |
| ២៩.តំណាង | CAM Asean | សមាជិក |
| ៣០.តំណាង | CCHR | សមាជិក |
| ៣១.តំណាង | HACC | សមាជិក |
| ៣២. តំណាង | MEC | សមាជិក |
| ៣៣. តំណាង | ឈូកស | សមាជិក |
| ៣៤. តំណាង | AUA | សមាជិក |

**ប្រការ៤**: ក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ មានតួនាទី និងភារៈកិច្ចដូចខាងក្រោម:

- ស្វែងរកការគាំទ្រផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងការអនុវត្តន៍ទាក់ទងនឹងក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ នឹងមេរោគអេដស៍ ជំងឺអេដស៍។
- រៀបចំពិនិត្យឡើងវិញ កែសម្រួល និងផ្តល់យោបល់គោលនយោបាយ គោលការណ៍ណែនាំ សេចក្តីប្រកាស និងសារាចរណ៍ណែនាំទាក់ទងនឹង មេរោគអេដស៍ ជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់។
- រៀបចំពិនិត្យឡើងវិញ កែសម្រួលផែនការយុទ្ធសាស្ត្រសំរាប់រយៈពេលវែង រយៈពេល

ខ្លី និងផែនការប្រតិបត្តិរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

- រៀបចំឧបករណ៍សំរាប់អន្តរាគមន៍ និងលើកកំពស់សមត្ថភាពបច្ចេកទេស និងសមត្ថភាពស្ថាប័នដល់សមាជិកក្រុមការងារ ដើម្បីរួមចំណែកអនុវត្តផែនការប្រតិបត្តិសំរាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។
- វិភាគស្ថានភាព និងការឆ្លើយតបដែលទាក់ទងនឹងការទទួលបានព័ត៌មាន និងសេវាដែលទាក់ទងនឹងមេរោគអេដស៍ ជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ ហើយទិន្នន័យដែលប្រមូលបានយកមកប្រើប្រាស់ ដើម្បីកំណត់អាទិភាពអន្តរាគមន៍លើក្រុមប្រឈមមុខខ្ពស់ និងទីតាំងភូមិសាស្ត្រដែលត្រូវធ្វើអន្តរាគមន៍។
- ការសហការជាមួយក្រុមការងារដទៃទៀតដើម្បីរួមចំណែកធ្វើអោយសម្រេចបាននូវគោលដៅសូចនាកររបស់ផែនការយុទ្ធសាស្ត្រជាតិលើកទីIV (NSP IV) គោលដៅទទួលបានជាសកល (UA) របាយការណ៍ស្តីពីបញ្ហាអេដស៍(UNGASS)និងឆ្លើយតបនឹងគោលការណ៍៩០៩០៩០ នាឆ្នាំ២០ ២០ និង៩៥ ៩៥ ៩៥ នាឆ្នាំ២០២៥ ដែលទាក់ទងនឹងក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ពិសេសសមាជិកក្រុមការងារដើម្បីអនុវត្តនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ដែលទាក់ទងនឹងក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។
- សហការជាមួយប្រទេសជិតខាងនិងក្នុងតំបន់ដើម្បីចែករំលែកនូវបទពិសោធន៍ដែលទាក់ទងនឹងមេរោគអេដស៍ ជំងឺអេដស៍ ក្នុងក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។
- ចលនាប្រភពធនធាន ដើម្បីពង្រីកបទអន្តរាគមន៍ និងបង្កើនគុណភាពសេវា ដែលទាក់ទងនឹងមេរោគអេដស៍ ជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ពិសេសក្រុមលាក់មុខ។
- សម្របសម្រួលក្នុងការប្រមូលទិន្នន័យសិក្សាវិភាគ និងផ្សព្វផ្សាយទិន្នន័យដែលទាក់ទងមេរោគអេដស៍ ជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ពិសេសក្រុមលាក់មុខដើម្បីប្រើប្រាស់ព័ត៌មានជាយុទ្ធសាស្ត្រ ក្នុងការរៀបចំនូវគោលនយោបាយគោលគោលការណ៍ណែនាំសេចក្តីប្រកាសនិងសារាចរណ៍ណែនាំ។

**ប្រការ៥**: អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាប្រធានក្រុមការងារថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។ ក្រុមការងារត្រូវជួបប្រជុំគ្នាជារៀងរាល់មួយត្រីមាសម្តង។ កិច្ចប្រជុំរបស់ក្រុមការងារនឹងអាចប្រព្រឹត្តឡើងជាលក្ខណៈបន្ទាន់ ប្រសិនបើក្នុង

ករណីចាំបាច់កិច្ចប្រជុំនឹងធ្វើឡើងនៅក្នុងការិយាល័យរបស់សមាជិកក្រុមការងារណាមួយ ហើយអាចផ្លាស់ប្តូរវេនគ្នាបន្ទាប់ពីមានកិច្ចប្រជុំពីរ ឬបីដងរួចមក ហើយរបាយការណ៍នៃកិច្ចប្រជុំនេះត្រូវផ្ញើរមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**ប្រការ៦**: ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ មានលេខាធិការដ្ឋានមួយនៅនាយកដ្ឋានបង្ការថែទាំ និងគាំទ្រនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ លេខាធិការដ្ឋាននេះ មានសមាសភាព និងតួនាទីភារៈកិច្ចដូចខាងក្រោម:

**ក.សមាសភាពលេខាធិការដ្ឋានៈ**

| | | |
|---|---|---|
| ១. លោកវេជ្ជ. វ៉ឹង យ៉ាណាត | ប្រធាននាយកដ្ឋានបង្កការ ថែទាំ និងគាំទ្រ | ប្រធាន |
| ២ .តំណាង | អង្គការUNAIDS | អនុប្រធាន |
| ៣. តំណាង | អង្គការFHI360 | អនុប្រធាន |
| ៤.លោកវេជ្ជ.អ៊ឹងសុវណ្ណៈ | ទទួលបន្ទុកការងារMSM&TG(អ.ជ.ប.ជ.អ) | សមាជិកអចិន្ត្រៃយ៍ |
| ៥.តំណាង | អង្គការKHANA | សមាជិក |
| ៦.តំណាង | អង្គការPSK | សមាជិក |
| ៧.តំណាង | អង្គការRHAC | សមាជិក |
| ៨.តំណាង | អង្គការMHSS | សមាជិក |
| ៩.តំណាង | អង្គការMHC | សមាជិក |
| ១០.តំណាង | អង្គការKHEMERA | សមាជិក |
| ១១.តំណាង | អង្គការPSC(អង្គការកម្ពុជាបំបាត់ឈឺចាប់) | សមាជិក |
| ១២.តំណាង | អង្គការ CSSD | សមាជិក |
| ១៣.តំណាង | អង្គការSIT | សមាជិក |
| ១៤.តំណាង | អង្គការAHF | សមាជិក |
| ១៥.តំណាង | អង្គការMEC | សមាជិក |
| ១៦.តំណាង | អង្គការPSC | សមាជិក |
| ១៧.តំណាង | បណ្តាញចតុមុខ(BC Network) | សមាជិក |
| ១៨. តំណាង | បណ្តាញអ្នកផ្ទុកមេរោគអេដស៍(CPN+) | សមាជិក |

**ខ.តួនាទី និងភារៈកិច្ចក្រុមការងារលេខាធិការដ្ឋានៈ**

-អនុវត្តការងារតាមសេចក្តីសម្រេចធ្វើឡើងដោយអង្គប្រជុំរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

- សម្របសម្រួលក្នុងការស្វែងរកការគាំទ្រផ្នែកនយោបាយយុទ្ធសាស្ត្រនិងការអនុវត្តន៍ទាក់ទងនឹងមេរោគអេដស៍ជំងឺអេដស៍ក្នុងក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់។
- ផ្តល់យោបល់ក្នុងការរៀបចំ ពិនិត្យឡើងវិញកែសម្រួល និងផ្តល់យោបល់នៅគោលនយោបាយ គោលការណ៍ណែនាំ សេចក្តីប្រកាស និងសារាចរណ៍ណែនាំ ដែលទាក់ទងនឹងមេរោគអេដស៍ ជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។
- ផ្តល់យោបល់ក្នុងការរៀបចំពិនិត្យឡើងវិញ កែសម្រួលផែនការយុទ្ធសាស្ត្ររយៈពេលវែង និងខ្លីនិងផែនការប្រតិបត្តិរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។
- ពិគ្រោះយោបល់ក្នុងការប៉ាន់ប្រមាណនិងការស្រាវជ្រាវទាំងឡាយដែលទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់។
- សិក្សារកបញ្ហា ឬកង្វះខាត ដើម្បីធ្វើការកែលំអរការអនុវត្តន៍កម្មវិធីបុរសស្រឡាញ់បុរស និងស្រីស្រស់។
- ចលនាប្រភពធនធានដែលអាចរកបាន ដើម្បីគាំទ្រសកម្មភាពក្រុមការងារលេខាធិការដ្ឋានក៏ដូចក្រុមការងារក្រុមការងារបច្ចេកទេសថ្នាក់ជាតិក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។
- ប្រមូលផ្តុំផែនការសកម្មភាពប្រចាំឆ្នាំរបស់អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ន ទាំងឡាយដែលធ្វើការទាក់ទងនឹងការងារក្រុមក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់ ដើម្បីរក្សាស្ថិតិការងារ និងសម្របសម្រួលស្របតាមផែនការយុទ្ធសាស្ត្រ។
- ធ្វើកំណត់ហេតុនៃកិច្ចប្រជុំថ្នាក់ជាតិ និងថ្នាក់តំបន់ដែលពាក់ព័ន្ធនឹងការងារក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។
- ផ្តល់ព័ត៌មានទាន់ពេលដល់សមាជិកក្រុមការងារបច្ចេកទេសអំពីបញ្ហានិងអន្តរាគមន៍ទាំងឡាយដែលពាក់ព័ន្ធនឹងការងារក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់នៅក្នុងប្រទេសនិងក្នុងតំបន់។
- រក្សាទំនាក់ទំនងរវាងក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ និងភាគីពាក់ព័ន្ធឯទៀត និងចែកចាយកំណត់ហេតុអង្គប្រជុំ និងរាយការណ៍ពីដំណើរការការងាររបស់លេខាធិការដ្ឋាន។
- ស្នើរឡើងនូវរបៀបវារៈសំរាប់កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។
- រៀបចំកម្មវិធីការចុះអភិបាលកិច្ចការងារអនុវត្តរបស់អង្គការក្រៅរដ្ឋាភិបាលជាដៃគូ។

- រៀបចំកម្មវិធីការចុះអភិបាលកិច្ចការងារអនុវត្តន៍សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជាដៃគូ។
- រៀបចំកម្មវិធីចុះសួរសុខទុក្ខបណ្តាញក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅតាមបណ្តារាជធានី ខេត្ត។
- ក្រុមការងារលេខាធិការដ្ឋានត្រូវមានកិច្ចប្រជុំប្រចាំខែ ក្នុងមួយខែម្តង។

**ប្រការ៧**: សមាជិកក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវគោរពតាមសេចក្តីសម្រេចចិត្តរួមរបស់ក្រុមការងារដែលធ្វើឡើងក្នុងការប្រជុំទាំងឡាយនៃក្រុមការងារ។

**ប្រការ៨**: និរាករណ៍សេចក្តីសម្រេចលេខ ០៦៨ អ.ជ.ប.ផ.អ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩។

**ប្រការ៩**: សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

អៀង-មូលី

<u>ចម្លងជូន៖</u>

. គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងពាក់ព័ន្ធ
. គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត
. អង្គការជាតិ អន្តរជាតិ ដែលពាក់ព័ន្ធ
. ឯកសារ កាលប្បវត្តិ